# I-ទីស្តីការគណៈរដ្ឋមន្ត្រី

រាជធានីភ្នំពេញ ; ថ្ងៃទី ១០ ខែ មិនា ឆ្នាំ ១៩៩៤

## អនុក្រឹត្យ

### អនុក្រឹត្យលេខ ១២ អនក្រ
### ស្តីពីការផ្ទេរសណ្ឋាគារ វិមានរាជរដ្ឋាភិបាល
### ( Hotel Gouvernement )

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- យោងព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេច ព្រះនរោត្តម សីហនុវរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសភាពការណ៍ចាំបាច់

**សំរេច**

**មាត្រា ១ :** ផ្ទេរសណ្ឋាគារវិមានរាជរដ្ឋាភិបាល ( Hotel Gouvernement ) ពីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ មកស្ថិតក្រោមការគ្រប់គ្រង របស់ទីស្តីការគណៈរដ្ឋមន្ត្រីវិញ ។

**មាត្រា ២ :** ចំ ះបុគ្គលិករាជការ ដែលបំរើការងារនៅសណ្ឋាគារនេះកន្លងមក ទីស្តីការគណៈរដ្ឋមន្ត្រីទទួលយកនូវចំនួនដែលក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិប្រគល់ជូន ។

**មាត្រា ៣ :** រាល់ចលនទ្រព្យ-អចលនទ្រព្យ បំរើអោយសណ្ឋាគារនេះកន្លងមក ត្រូវប្រគល់ជូនទីស្តីការគណៈរដ្ឋមន្ត្រី គ្រប់គ្រង និង ប្រើប្រាស់តទៅ ។

**មាត្រា ៤ :** បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយ និងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ គ្រប់ស្ថាប័ន ក្រសួង រដ្ឋលេខាធិការដ្ឋាន ត្រូវទទួលអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ។

**មាត្រា ៦ :** អនុក្រឹត្យនេះមានអានុភាពអនុវត្តិ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

***

*រាជធានីភ្នំពេញ , ថ្ងៃទី ១០ ខែ មិនា ឆ្នាំ ១៩៩៤*

## អនុក្រឹត្យលេខ ១៣ អនក្រ
## ស្តីពីការបង្កើតក្រុមប្រឹក្សាអ្នកច្បាប់

រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុវរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-យោងតាមសំណូមពរការងារចាំបាច់

### សំរេច

**មាត្រា ១ :** ត្រូវបានបង្កើត ក្រុមប្រឹក្សាអ្នកច្បាប់ ដែលមានសមាសភាពដូចតទៅ :

| | | |
|---|---|---|
| ១-ឯកឧត្តម **សុខ អាន** | រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី | ជាសហប្រធាន |
| ២-ឯកឧត្តម **វ៉េង សេរីវុឌ្ឍ** | រដ្ឋមន្ត្រីទីស្តីគណៈរដ្ឋមន្ត្រី | ជាសហប្រធាន |
| ៣-ឯកឧត្តម **សាយ បូរី** | រដ្ឋលេខាធិការទំនាក់ទំនងជាមួយសភា | អនុប្រធាន |
| ៤-ឯកឧត្តម **ហេង ចន្ទមុនីរ៉ាត** | ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រីទី ២ | អនុប្រធាន |
| ៥-ឯកឧត្តម **អ៊ឹក ចិចុន** | ទីប្រឹក្សាសម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី ១ | សមាជិក |